# ការវាយតម្លៃស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (CCA)/ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ (DRR) បញ្ជ្រាបក្នុងផែនការវិនិយោគឃុំ (CIP)/ផែនការអភិវឌ្ឍន៍ឃុំ (CDP) ដោយឆ្លុះបញ្ចាំងពីគោលការណ៍រួមបន្សាំ (JPA)

ខែមករា ឆ្នាំ២០១៩





ប្រទេសកម្ពុជាជាប្រទេសកសិកម្ម ដែលងាយរងគ្រោះដោយសារឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ហើយប្រព័ន្ធបន្សាំរបស់មនុស្សនៅមានកម្រិតក្នុងការឆ្លើយតបទៅនឹងផលប៉ះពាល់ដោយព្រឹត្តិការណ៍អាកាសធាតុអាក្រក់បំផុត ដូចជា៖ ទឹកជំនន់ និងគ្រោះរាំងស្ងួត (ក្រសួងបរិស្ថាន ២០១៥)។ ការប្រែប្រួលអាកាសធាតុជាបញ្ហាប្រឈមយ៉ាងពិតប្រាកដរបស់ប្រទេសកម្ពុជា ហើយសេដ្ឋកិច្ច និងជីវភាពរស់នៅត្រូវបានជ្រៀតជ្រែកដោយឥទ្ធិពលរបស់វា ដែលតែងតែកើតឡើងជាញឹកញាប់ក្នុងប្រទេសនេះ។ ដោយសារតែសមត្ថភាពបន្សាំទាបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការពឹងផ្អែកខ្ពស់ លើវិស័យកសិកម្ម និងការប្រើប្រាស់ធនធានធម្មជាតិរបស់ប្រជាជនមូលដ្ឋាន ដែលងាយប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ កម្ពុជាបានក្លាយទៅជាប្រទេសដែលងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ(ក្រសួងបរិស្ថាន ២០១៣)។

ប្រទេសកម្ពុជាចាត់ទុកថាជាប្រទេសមួយដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិដោយសារតែសមត្ថភាពបន្សាំទាប និងប្រព័ន្ធភាពធន់នៅទន់ខ្សោយ ការបញ្ជ្រាបសកម្មភាពទាំងនេះក្នុងផែនការវិនិយោគឃុំ (CIP)/ផែនការអភិវឌ្ឍន៍ឃុំ(CDP) ដោយឆ្លុះបញ្ចាំងគោលការណ៍រួមស្តីពីការបន្សាំ (JPA) គឺជាកិច្ចខិតខំប្រឹងប្រែងដ៏មានសារៈ

សំខាន់បំផុតដែលត្រូវរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ(CoCs) និងអង្គការមិនមែនរដ្ឋាភិបាល (NGOs)។កន្លងមកមានឯកសារសិក្សាស្រាវជ្រាវតិចតួចដែលបានសិក្សាប៉ាន់ប្រមាណពីការបន្សាំ និងគ្រោះភ័យនៃគ្រោះមហន្តរាយបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ ដែលជាប់ពាក់ព័ន្ធនឹងគោលការណ៍រួមស្ដីពីការបន្សាំ (JPA)។ ដោយយល់ឃើញបែបនេះ ការសិក្សាគ្រប់ជ្រុងជ្រោយមួយស្ដីពីលទ្ធភាពនៃការបញ្ជ្រាប CCA/DRR ទៅក្នុងគោលការណ៍រួមស្ដីពីការបន្សាំ (JPA) នៅតែជាការសិក្សាមួយដែលចាំបាច់។

ឯកសារនេះមានគោលបំណងដើម្បីស៊ើបអង្កេតមើលថាតើក្រុមប្រឹក្សាឃុំបានដើរតួនាទីយ៉ាងដូចម្ដេចក្នុងការបញ្ជ្រាបការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (CCA)/ ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ (DRR)។ ក្នុងកិច្ចការស្រាវជ្រាវនេះ មានអភិក្រមពីរសំខាន់ៗសម្រាប់ការងារទីវាល និងការប្រមូលទិន្នន័យ៖ ១) ការសិក្សាឯកសារនិងទិន្នន័យដែលមានស្រាប់ និង ២)ការងារចុះសិក្សានៅទីវាលសម្រាប់ទិន្នន័យបឋមត្រូវបានអនុវត្ត ក្នុងគោលបំណងដើម្បីពិនិត្យមើលលម្អិតថាតើត្រូវដាក់បញ្ចូល CCA/DRR ក្នុងគោលការណ៍រួមស្ដីពីការបន្សាំយ៉ាងដូចម្ដេច? ការសំយោគឯកសារជាច្រើនលើ CCA/DRR ត្រូវបានយកមកពិនិត្យក្នុងគោលបំណងដើម្បីកែលម្អរ វិធីសាស្ត្រនៃការសិក្សានេះឱ្យកាន់តែប្រសើរ។ ជាពិសេស ឃុំចំនួនពីរ៖ ១) សង្កាត់បារាយណ៍ ខណ្ឌដូនកែវ ខេត្តតាកែវ និង ២)ឃុំស៊ាងឃ្វៀង ស្រុកកំចាយមា ខេត្តព្រៃវែង ត្រូវបានជ្រើសរើសជាករណីសិក្សាសម្រាប់ការវិភាគគុណភាព។

## ការរកឃើញសំខាន់ៗ៖
## ការសិក្សាបានបង្ហាញថា៖

១. កម្មវិធីវិនិយោគឃុំ/កម្មវិធីអភិវឌ្ឍន៍ឃុំ (CIP/CDP) ត្រូវបានបង្កើតឡើងដោយផ្ដោតសំខាន់លើអាទិភាពមូលដ្ឋានដែលបានស្នើឡើងដោយប្រជាពលរដ្ឋមូលដ្ឋាន។ តែការអនុវត្តកម្មវិធីវិនិយោគឃុំ/កម្មវិធីអភិវឌ្ឍន៍ឃុំ ហាក់ដូចជាទទួលបានលទ្ធផលតិចតួចណាស់ដោយសារតែមិនមានមូលនិធិខាងក្នុងមូលដ្ឋានផ្ទាល់។ ប្រភពមូលនិធិសំខាន់បានមកពីរដ្ឋាភិបាលថ្នាក់ជាតិ និងអង្គការ ក្នុងទំហំតូច និងមិនប្រាកដជា ដែលអាចឆ្លើយតបនឹងតម្រូវការមូលដ្ឋានបាន។

២. ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនៅតែជារបៀបវារៈអភិវឌ្ឍន៍ដ៏សំខាន់ ដែលបានចាត់អាទិភាពដោយរដ្ឋាភិបាលថ្នាក់កណ្ដាល និងប្រជាជនមូលដ្ឋាន។ ទោះជាយ៉ាងណា ប្រជាជនមូលដ្ឋានក៏បានលើកឡើងនូវតម្រូវការរបស់ពួកគាត់ ដើម្បីកែលម្អសេដ្ឋកិច្ចសង្គមរបស់

គាត់រួមទាំងការបន្សាំការប្រែប្រួលអាកាសធាតុ / ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយក្នុងកម្មវិធីវិនិយោគឃុំ/កម្មវិធីអភិវឌ្ឍន៍ឃុំ ដែលគេរំពឹងថានឹងមានការទទួលខុសត្រូវដោយអង្គការសង្គមស៊ីវិល។

៣. ការបញ្ជ្រាប CCA/DRR ហាក់ដូចជាមានកម្រិតទាប បើផ្អែកលើករណីសិក្សានៃឃុំទាំងពីរ។ មូលនិធិដែលអាចរកបានសម្រាប់ការកសាងផ្លូវមិនបានវិភាជន៍សម្រាប់ការបញ្ជ្រាប CCA/DRR នោះទេ។ កម្មវិធីអភិវឌ្ឍន៍របស់រដ្ឋាភិបាលថ្នាក់កណ្ដាល អង្គការសង្គមស៊ីវិល និងក្រុមប្រឹក្សាឃុំហាក់ដូចជាមានភាពខុសគ្នានាពេលបច្ចុប្បន្ន។

៤. ទំហំការងារដែលបានអនុវត្តដោយក្រុមប្រឹក្សាឃុំនៅមានកម្រិតដោយសារតែសមត្ថភាពធនធានមនុស្សរបស់ពួកគាត់ និងការទទួលបានហិរញ្ញវត្ថុ។ ក្រុមប្រឹក្សាឃុំប្រតិបត្តិគម្រោងនឹងមិនបានល្អនោះទេ ប្រសិនបើគ្មានសមត្ថភាពធនធានមនុស្ស ឬការគាំទ្របច្ចេកទេសពីមន្ត្រីថ្នាក់ខេត្ត/ស្រុក និងមន្ត្រីអង្គការនោះទេ។

៥. មានបញ្ហាប្រឈមចំនួន៤ ដែលរួមមាន៖ ការសម្រេចចិត្តរបស់អាជ្ញាធរនៅមានកម្រិតមិនបានប្រតិបត្តិការដោយស្វ័យភាព កង្វះគណនេយ្យភាព និងការទទួលខុសត្រូវមានកម្រិតទាប។ នៅពេលអនាគត ការបញ្ជ្រាប CCA/DRR គួរតែត្រូវបានកែលម្អ តាមរយៈការពង្រឹងសមត្ថភាព ការកៀរគរធនធានប្រកបដោយប្រសិទ្ធភាពនិងជំនួយផ្នែកគាំទ្របច្ចេកទេស។ ជាពិសេស រដ្ឋាភិបាល ថ្នាក់កណ្ដាល អង្គការ និងក្រុមប្រឹក្សាឃុំគួរតែមានរបៀបវារៈអភិវឌ្ឍន៍តែមួយ។

## តើយើងចាំបាច់ត្រូវធ្វើអ្វីបន្ថែមទៀត

**ជំរុញការអនុវត្ត/អភិវឌ្ឍន៍គោលនយោបាយ៖** ផ្អែកលើវិសហមជ្ឈការ ក្រុមប្រឹក្សាឃុំត្រូវបានផ្ទេរសមត្ថកិច្ចក្នុងការអភិវឌ្ឍឃុំ តាមរយៈការអនុវត្តកម្មវិធីវិនិយោគឃុំ និងកម្មវិធីអភិវឌ្ឍន៍ឃុំ។ ចាប់តាំងពីឆ្នាំ២០០០មក មានក្របខណ្ឌគតិយុត្ត និងគោលនយោបាយជាច្រើនជាឧទាហរណ៍ ច្បាប់ស្ដីពីការគ្រប់គ្រងគ្រោះមហន្តរាយក្នុងប្រទេសកម្ពុជា ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (២០១៤-២០២៣) កម្មវិធីអភិវឌ្ឍប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩) កម្មវិធីអភិវឌ្ឍន៍ជំហានទី១ (២០១០-២០១៣) កម្មវិធីអភិវឌ្ឍន៍ជំហានទី២ (២០១៤-២០១៦) កម្មវិធីអភិវឌ្ឍន៍ជំហានទី៣ (២០១៦-២០១៨) និងផែនការប្រតិបត្តិប្រចាំឆ្នាំ និងយុទ្ធសាស្ត្រតស៊ូមតិលើការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំឡើង។ ក្របខណ្ឌគតិយុត្តិដែលមានស្រាប់គឺជាការចាំបាច់

ដើម្បីប្រែក្លាយវាទៅជាសកម្មភាពអនុវត្តជាក់ស្ដែង។ ក្នុងបរិបទនេះ ភ្នាក់ងារទាំងអស់គួរតែធ្វើការរួមគ្នាឱ្យបានជិតស្និត។ តម្រូវការមូលដ្ឋានត្រូវតែបំពេញនៅពេលដែលក្រុមប្រឹក្សាឃុំទទួលបានការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់អនុវត្តកម្មវិធីវិនិយោគឃុំ/កម្មវិធីអភិវឌ្ឍន៍ឃុំ ដើម្បីឆ្លើយតបនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងគ្រោះភ័យនៃគ្រោះមហន្តរាយ (CCA/DRR)។

**រដ្ឋាភិបាលថ្នាក់កណ្ដាល និងថ្នាក់ខេត្ត៖** បង្កើនមូលនិធិឃុំ/សង្កាត់ប្រចាំឆ្នាំ និងសមត្ថកិច្ចក្នុងការធ្វើការសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំពិតជាមានសារៈសំខាន់ណាស់សម្រាប់ការធ្វើសមាហរណកម្ម និងបញ្ជ្រាប គម្រោងការបន្សាំ ការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយក្នុងការអនុវត្ត កម្មវិធីវិនិយោគឃុំ/កម្មវិធីអភិវឌ្ឍន៍ឃុំ។ បើទោះបីជា គោលនយោបាយ ក្របខណ្ឌគតិយុត្តិ យុទ្ធសាស្ត្រ និងផែនការសំខាន់ៗត្រូវបានអនុម័ត មូលនិធិសម្រាប់ការអនុវត្ត សកម្មភាពនៅតែមានកម្រិតទាបនៅឡើយ។ យោងតាមកម្មវិធីវិនិយោគឃុំបារាយណ៍ឆ្នាំ២០១៧ និងឃុំស៊ាងឃ្វៀង ឆ្នាំ២០១៥ សកម្មភាពចំនួន៣០%ប៉ុណ្ណោះ បានទទួលមូលនិធិដើម្បីអនុវត្ត។ ជាលទ្ធផល គម្រោងអភិវឌ្ឍន៍ដែលបានស្នើឡើងជាច្រើនមិនបានអនុវត្តន៍។

**បញ្ជ្រាប** CCA/DRR **តាមរយៈការអនុវត្ត ផែនការវិនិយោគឃុំ**(CIP) **និង ផែនការអភិវឌ្ឍន៍ឃុំ**(CDP)**៖** រៀងរាល់ឆ្នាំ សកម្មភាពដែលពាក់ព័ន្ធនឹងអន្តរាគមន៍នៃ CCA/DRR ត្រូវបានដាក់បញ្ចូលក្នុង CDP និង CIP ប៉ុន្តែក្រុមប្រឹក្សាឃុំមិនបានអនុវត្តគម្រោងណាមួយនោះទេ ដោយសារតែកង្វះមូលនិធិសម្រាប់ពួកគាត់។ មូលនិធិឃុំ/សង្កាត់ដែលបានផ្ទេរពីក្រសួងមហាផ្ទៃបានវិភាជន៍សម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ខណៈដែលមូលនិធិដែលបានពីការធ្វើសមាហរណកម្មពីអង្គការសង្គមស៊ីវិលនៅមានកម្រិតនៅឡើយ។ នៅដំណាក់កាលនេះ ការបញ្ជ្រាប CCA/DRR នៅកម្រិតឃុំគួរតែកើតឡើង នៅពេលដែលមូលនិធិប្រចាំឆ្នាំសម្រាប់ក្រុមប្រឹក្សាឃុំត្រូវបានវិភាជន៍ជាក់លាក់សម្រាប់ CCA/DRR ដែលពាក់ព័ន្ធនឹងមូលនិធិគម្រោងអភិវឌ្ឍន៍ពីឃុំ/សង្កាត់ ឬពីអង្គការ។ នាពេលបច្ចុប្បន្ន មូលនិធិឃុំសង្កាត់មានកម្រិតណាស់ អញ្ចឹងហើយបានជាការចូលរួមហិរញ្ញវត្ថុពីអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍ នឹងធ្វើឱ្យផ្នែកនេះអាចកើតឡើងបាន។ កំឡុងពេលរៀបចំកម្មវិធីវិនិយោគឃុំ អង្គការប្រហែលជាត្រូវធ្វើការជាមួយក្រុមប្រឹក្សាឃុំដើម្បីសម្របសម្រួលក្នុងការចាត់អាទិភាព និងការផ្ដល់មូលនិធិចំពោះសកម្មភាពអាទិភាព ដែលបានស្នើឡើងដោយប្រជាជនមូលដ្ឋាន

ក្នុងគោលបំណងដើម្បីកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយធម្មជាតិ។

**សម្រាប់ក្រុមប្រឹក្សាឃុំ និងអង្គការមិនមែនរដ្ឋាភិបាល៖** ការពង្រឹងសមត្ថភាពរយៈពេលវែងសម្រាប់ក្រុមប្រឹក្សាឃុំគួរតែត្រូវរៀបចំឡើងសម្រាប់ការធ្វើផែនការ និងការកៀរគរមូលនិធិកាន់តែប្រសើរឡើង។ ក្នុងសហគមន៍មូលដ្ឋានប្រទេសកម្ពុជា កម្រិតអប់រំមូលដ្ឋានក្នុងចំណោមប្រជាជនទូទៅនៅមានកម្រិតទាប។ បើទោះបីជារដ្ឋាភិបាលថ្នាក់កណ្តាលបានពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំតាំងពីឆ្នាំ២០០២ក្តីវឌ្ឍនភាពជាច្រើនត្រូវតែធ្វើឡើងតាមរយៈដំណើរការរៀបចំផែនការដោយមានការចូលរួម។ នៅចុងបញ្ចប់ ក្រុមប្រឹក្សាឃុំទាមទារនូវការពង្រឹងសមត្ថភាពតាមរយៈ ផែនការរយៈពេលវែង ឧទាហរណ៍ ការកៀរគរមូលនិធិ និងការគ្រប់គ្រងធនធាន ដែលនឹងសម្រួលដល់ពួកគាត់ដើម្បីប្រតិបត្តិសេវាសង្គម និងបញ្ជ្រាប CCA/DRR ទៅក្នុង CIP/CDP ក្នុងរយៈពេលវែងដោយខ្លួនឯង។ នៅពេលបច្ចុប្បន្ន អង្គការជាតិ និងអន្តរជាតិគឺជាស្ថាប័នដែលសមស្របបំផុតដើម្បីគាំទ្រការពង្រឹងសមត្ថភាពរយៈពេលវែង៖ វាជាមធ្យោបាយដើម្បីពាំនាំគោលដៅរបស់ពួកគេនៅកម្រិតគ្រួសារទៅជាកម្រិតសហគមន៍។ ពួកគេមិនមានហិរញ្ញវត្ថុ និងធនធានមនុស្សគ្រប់គ្រាន់ប៉ុន្តែគេមានបទពិសោធន៍បន្ថែមដ៏ទូលំទូលាយក្នុងការងារអភិវឌ្ឍន៍សហគមន៍និងគ្រប់គ្រងធនធាន។

**ពង្រឹងសមត្ថភាពគណៈកម្មាការក្រុមប្រឹក្សាឃុំ** គួរតែត្រូវផ្តល់រយៈពេលវែងលើដំណើការនៃការធ្វើការបណ្តើរ រៀនសូត្របណ្តើរ។ និស្សិតដែលទើបបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យគួរតែត្រូវបានជ្រើសរើស ដើម្បីគាំទ្របច្ចេកទេសលើប្រតិបត្តិការប្រចាំថ្ងៃ ដោយផ្តល់ឱ្យពួកគេនូវបរិយាកាសការងារល្អ និងការពង្រឹងសមត្ថភាព។ តួនាទីរបស់អង្គការជាតិ អង្គការអន្តរជាតិ និងរដ្ឋាភិបាលនៅថ្នាក់ខេត្ត និងស្រុកគួរតែផ្តល់ការគាំទ្រការណែនាំ និងបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ និងជំនួយបច្ចេកទេស លើផ្នែកការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយគ្រោះមហន្តរាយការកៀរគរជំនួយ និងការគ្រប់គ្រងផែនការវិស័យកសិកម្ម និងមិនមែនកសិកម្ម ដើម្បីកែលម្អជីវភាពសហគមន៍មូលដ្ឋាន។ ការពង្រឹងសមត្ថភាពតាមរយៈការធ្វើការបណ្តើរ រៀនសូត្របណ្តើរ និងដោយមានជំនួយបច្ចេកទេសអាចជំរុញការប្រតិបត្តិប្រចាំថ្ងៃ និងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំលើការងារដែលស្នើឡើងខាងលើកាន់តែប្រសើរឡើង។ ប្រភេទនៃសេវាសង្គម និងសេវាសាធារណៈ ដែលនឹងធ្វើឱ្យក្រុមប្រឹក្សាឃុំកាន់មានសម្ថភាពច្បាស់លាស់រួមមានសកម្មភាពបង្កើនប្រាក់ចំណូល(IGAs)ពី

វិស័យកសិកម្មនិងមិនមែនកសិកម្ម ការថែរក្សាសុខភាព ការអប់រំមូលដ្ឋាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការចំណាកស្រុក និងសន្តិសុខសង្គម។

**គែលម្ពការអនុវត្តតាមគោលការណ៍រួមបន្សាំ នឹងការប្រែប្រួលអាកាសធាតុ (JPA) នៅថ្នាក់ក្រុមប្រឹក្សាឃុំ** ក្នុងគោលបំណងដើម្បីទទួលយកឧបករណ៍នេះនៅកម្រិតឃុំ អង្គការបានដើរតួនាទីយ៉ាងសំខាន់បំផុតក្នុងការផ្តល់ការពង្រឹងសមត្ថភាពការបង្វឹកបង្វឺន និងគាំទ្រហិរញ្ញវត្ថុដើម្បីគាំទ្រការអនុវត្តឧបករណ៍ដោយមានការចូលរួម ដែលធានាគោលនយោបាយ និងផែនការជាតិ សម្រេចតាមសេចក្តីត្រូវការ និងបំពេញសិទ្ធិនៃជនដែលងាយរងគ្រោះបំផុតដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ ក្នុងអំឡុងពេលធ្វើការវាយតម្លៃដោយការអនុវត្តគោលការណ៍រួមស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (JPA) របស់ក្រុមប្រឹក្សាឃុំនៅមានកម្រិត អង្គការគួរតែចូលរួមជាមួយក្រុមប្រឹក្សាឃុំក្នុងការពង្រឹងសមត្ថភាពក្នុងអំឡុងពេលដែលពួកគេ ធ្វើកិច្ចការអនុលោមតាមគោលការណ៍រួមស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (JPA)។ តាមរយៈការអនុវត្តបែបនេះ ក្រុមប្រឹក្សាឃុំនឹងអាចប្រើប្រាស់ឧបករណ៍នេះបាន។ ការពិតសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំនៅមានកម្រិត និងមិនមានធនធានណាមួយពីភ្នាក់ងាររដ្ឋាភិបាលដែលអាចជួយក្រុមប្រឹក្សាឃុំ ដើម្បីរៀនសូត្រលើការអនុវត្តគោលការណ៍រួមស្តីពីការបន្សាំនោះទេ។ លើសពីនេះទៅទៀត អង្គការប្រហែលជាផ្តល់ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុដល់ក្រុមប្រឹក្សាឃុំកំឡុងពេលរៀបចំកម្មវិធីវិនិយោគឃុំ/កម្មវិធីអភិវឌ្ឍន៍ឃុំ៕

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
*The NGO Forum on Cambodia*
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
*Working Together for Positive Change*

អាសយដ្ឋានអគារលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន
ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ ប្រទេសកម្ពុជា

Tel: (855-23) 214 429
Fax: (855-23) 994 063
E-mail: ngoforum@ngoforum.org.kh
https://www.facebook.com/ngoforumoncambodia
https://twitter.com/thengoforum
https://bit.ly/GooglePlus-ngoforumoncambodia
https://www.youtube.com/user/ngofoncambodia
Website: http://www.ngoforum.org.kh